# ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានរៀបចំកិច្ចប្រជុំលើកទី២៣ ក្រុមការងារផលិតផល ផ្នែកផលិតផលផលិតពីកៅស៊ូ ( RBPWG ) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រព្រឹត្តិទៅពីថ្ងៃទី២៣ ដល់ ២៥ ខែសីហា ឆ្នាំ២០១៦ នៅខេត្តសៀមរាប




តាមខ្លឹមសារនៃសេចក្តីប្រកាសព័ត៌មានរបស់វិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម កិច្ចប្រជុំនេះមានការចូលរួមពី គ្រប់អង្គភាពស្តង់ដារជាតិ នៃបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានសារៈសំខាន់សម្រាប់កម្ពុជា ទោះបីនៅពេលបច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានឧស្សាហកម្មធំៗ ផ្នែកផលិតផលផលិតពីកៅស៊ូក៏ដោយ ក៏យើងមានផលិតផលកៅស៊ូផលិតពីកៅស៊ូធម្មជាតិ ដែលផលិតផលទាំងនោះត្រូវបានអនុលោមទៅតាមស្តង់ដាររបស់អាស៊ាន តាមរយៈកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកចូលជាធរមាន ដើម្បីកាត់បន្ថយនូវរបាំងបច្ចេកទេសមិនចាំបាច់ ដូចជាការកាត់បន្ថយចំនួនធ្វើតេស្ត ចំនួនវិញ្ញាបនប័ត្រ និងចំនួននៃការត្រួតពិនិត្យ ដែលជាមូលដ្ឋានសម្រាប់ជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មលើផលិតផលផលិតពីកៅស៊ូ និងផលិតផលកៅស៊ូក្នុងទីផ្សារតំបន់ ក៏ដូចជាទីផ្សារពិភពលោក។

ម្យ៉ាងវិញទៀតកម្ពុជា អាចប្រើប្រាស់នូវលទ្ធផល នៃកិច្ចប្រជុំរបស់ក្រុមការងារផលិតផលនេះ ចូលរួមកាត់បន្ថយការចំណាយថ្លៃដើមមិនចាំបាច់ បង្កើនភាពប្រកួតប្រជែងដល់ឧស្សាហកម្មក្នុងស្រុក ដែលជាកត្តាមូលដ្ឋានមួយ សម្រាប់ទាក់ទាញវិនិយោគក្នុង និងក្រៅប្រទេស ដើម្បីពង្រីកវិស័យឧស្សាហកម្មកៅស៊ូ នាពេលអនាគតដ៏ខ្លីខាងមុខនេះ។







LAO PDR


MALAYSIA


THE 23
RBPWG)


THE 23rd MEETING OF THE ACCSQ : RUBBER-BASED PRODUCT WORKING GROUP (RBPWG)
AND ITS RELATED MEETINGS
23 - 25 August 2016 Siem Reap, Cambodia
APSARA PALACE Resort and Conference Center